ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

**សេចក្តីប្រកាសព័ត៌មាន**

**លទ្ធផលនៃកិច្ចសន្ទនាតាមទូរស័ព្ទរវាង ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ ម៉ារីស ផេន រដ្ឋមន្ត្រីការបរទេស និងជារដ្ឋមន្ត្រីកិច្ចការនារីអូស្ត្រាលី**
**នៅថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០២១**

------

នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១ ឯកឧត្តម ប្រាក់ **សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា បានពិភាក្សាការងារតាមទូរស័ព្ទជាមួយលោកជំទាវ **ម៉ារីស ផេន** រដ្ឋមន្ត្រីការបរទេស និងជារដ្ឋមន្ត្រីកិច្ចការនារីអូស្ត្រាលី។ រដ្ឋមន្ត្រីការបរទេសទាំងពីរបានពិភាក្សាគ្នាអំពីកិច្ចសហប្រតិបត្តិការទ្វេភាគី និងបញ្ហាតំបន់ និងអន្តរជាតិមួយចំនួនដែលជាចំណាប់អារម្មណ៍ និងការបារម្ភរួមគ្នា រួមទាំងភាពជាដៃគូសន្តិសុខត្រីភាគីអូស្ត្រាលី-អង់គ្លេស-អាមេរិក (AUKUS) ដែលទើបត្រូវបានបង្កើតឡើងនាពេលថ្មីនេះផងដែរ។

រដ្ឋមន្ត្រីការបរទេសទាំងពីរបានកត់សម្គាល់ដោយការពេញចិត្តចំពោះវឌ្ឍនភាពនៃទំនាក់ទំនងទ្វេភាគីរវាងប្រទេសទាំងពីរ ដោយរួមបញ្ចូលទាំងវឌ្ឍនភាពស្ថិតក្រោមភាពជាដៃគូមេគង្គ-អូស្ត្រាលី ផងដែរ។ រដ្ឋមន្ត្រីការបរទេសទាំងពីរបានអះអាងជាថ្មីនូវការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការធ្វើការកាន់តែជិតស្និទ្ធដើម្បីពង្រឹងបន្ថែមទៀតនូវទំនាក់ទំនង ទាំងនៅក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី ដើម្បីផលប្រយោជន៍ទៅវិញទៅមករវាងប្រទេសទាំងពីរ សម្រាប់សន្តិភាព ស្ថិរភាព និងវិបុលភាពនៅក្នុងតំបន់ជាពិសេស នៅពេលដែលកម្ពុជាធ្វើជាប្រធានអាស៊ាននៅក្នុងឆ្នាំក្រោយ។

ចំពោះបញ្ហាតំបន់ លោកជំទាវ **ម៉ារីស ផេន** បានជម្រាបជូន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ **សុខុន** អំពីបញ្ហានានាពាក់ព័ន្ធនឹងភាពជាដៃគូ AUKUS និងគោលបំណងរបស់ភាពជាដៃគូនេះ។ **លោកជំទាវ** បានសង្កត់ធ្ងន់ថា AUKUS ត្រូវបានបង្កើតឡើងដើម្បីប្រយោជន៍ទូទៅ ដើម្បីសន្តិភាព វិបុលភាព និងសន្តិសុខនៅក្នុងតំបន់ឥណ្ឌូ-ប៉ាស៊ីហ្វិក ហើយគ្មានចេតនាណាមួយដើម្បីទទួលបានអាវុធនុយក្លេអ៊ែរ និងសមត្ថភាពនុយក្លេអ៊ែរស៊ីវិលនោះទេ។ បន្ថែមលើនេះផងដែរ AUKUS មិនមែនជាការបន្ថែមទៅលើការប្រកួតប្រជែងសព្វាវុធនៅក្នុងតំបន់នោះទេ។ ជាផ្នែកមួយនៃ AUKUS ប្រទេសអូស្ត្រាលី នឹងអាចទទួលបាននាវាមុជទឹកដើរដោយថាមពលនុយក្លេអ៊ែរ ដើម្បីបង្កើនសមត្ថភាពរបស់កងនាវាចរ

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

អូស្ត្រាលី។ **លោកជំទាវ** បានបញ្ជាក់ជាថ្មីថា ប្រទេសអូស្ត្រាលីប្តេជ្ញាចិត្តចំពោះកាតព្វកិច្ចនៃការមិនរីកសាយភាយនៃអាវុធនុយក្លេអ៊ែរ និងធ្វើការយ៉ាងជិតស្និទ្ធជាមួយទីភ្នាក់ងារថាមពលអាតូមិកអន្តរជាតិ (IAEA) ។

លោកជំទាវ **ម៉ារីស ផេន** ក៏បានអះអាងជាថ្មីនូវការបន្តគាំទ្ររបស់អូស្ត្រាលីចំពោះមជ្ឈភាពអាស៊ាន និងគោលការណ៍នានាដែលមានចែងនៅក្នុងទស្សនៈវិស័យអាស៊ានស្តីពីឥណ្ឌូ-ប៉ាស៊ីហ្វិក (AOIP) ។ **លោកជំទាវ**បានសង្កត់ធ្ងន់ថា ប្រទេសអូស្ត្រាលីប្តេជ្ញាចិត្តប្រកាន់ខ្ជាប់នូវកាតព្វកិច្ចក្រោមសន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការ (TAC) សន្ធិសញ្ញាតំបន់ប៉ាស៊ីហ្វិកខាងត្បូងគ្មានអាវុធនុយក្លេអ៊ែរ (SPNWFZ) និងតំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ (SEANWFZ)។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានថ្លែងអំណរគុណចំពោះ លោកជំទាវ **ម៉ារីស ផេន** សម្រាប់ព័ត៌មានពាក់ព័ន្ធ AUKUS ។ **ឯកឧត្តម ប្រាក់ សុខុន** បានកោតសរសើរចំពោះការប្តេជ្ញាចិត្តរបស់អូស្ត្រាលីក្នុងការគាំទ្រមជ្ឈភាពអាស៊ាន និងពង្រីកការចូលរួមរបស់ខ្លួននៅក្នុងកិច្ចព្រមព្រៀង និងសន្ធិសញ្ញានានា ជាពិសេសសន្ធិសញ្ញា TAC SEANWFZ និងតំបន់សន្តិភាព សេរីភាព និងអព្យាក្រឹត (ZOPFAN)។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានលើកទឹកចិត្តដល់អូស្ត្រាលីឱ្យមានការចូលរួមប្រកបដោយស្ថាបនាជាមួយអាស៊ាន តាមរយៈយន្តការនានាដែលដឹកនាំដោយអាស៊ាន នៅក្នុងការកសាងការទុកចិត្ត និងជំនឿជាក់លើគ្នាទៅវិញទៅមក សំដៅការពារបាននូវនិម្មាបនកម្មតំបន់ដែលបើកចំហ មានតម្លាភាព ប្រកបដោយបរិយាប័ន្ន និងឈរលើគោលការណ៍ច្បាប់។ **ឯកឧត្តម** បានគូសបញ្ជាក់ថា កម្ពុជាដែលជាប្រទេសធ្លាប់ឆ្លងកាត់សង្គ្រាម ការបំផ្លិចបំផ្លាញ និងការឈឺចាប់រាប់មិនអស់ជាច្រើនទសវត្សរ៍ ចង់ឃើញតំបន់ទាំងមូលនៅតែរក្សាបាននូវសន្តិភាព ស្ថិរភាព និង វិបុលភាព ហើយ និងបានសង្ឃឹមថា AUKUS នឹងមិនបន្ថែមសាំងទៅលើការប្រកួតប្រជែងដែលកំពុងមានស្ថានភាពមិនល្អស្រាប់ និងបង្កើនភាពតានតឹងបន្ថែមទៀតនោះទេ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានលើកទឹកចិត្តដល់អូស្ត្រាលី និងដៃគូខាងក្រៅរបស់អាស៊ានឱ្យគាំទ្របន្ថែមទៀតដល់វិស័យអាទិភាពទាំងបួននៃកិច្ចសហប្រតិបត្តិការ ដែលមានចែងនៅក្នុងទស្សនៈវិស័យអាស៊ាន ស្តីពីឥណ្ឌូប៉ាស៊ីហ្វិក (AOIP) រួមមាន កិច្ចសហប្រតិបត្តិការលំហសមុទ្រ ការតភ្ជាប់ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ (SDGs) និងកិច្ចសហប្រតិបត្តិការក្នុងវិស័យសេដ្ឋកិច្ច និងវិស័យផ្សេងៗទៀត។

ភាគីទាំងពីរ ក៏បានផ្លាស់ប្តូរទស្សនៈគ្នាលើបញ្ហាតំបន់បន្ទាន់ ដែលមានសារៈសំខាន់ចំពោះសន្តិភាព សន្តិសុខ និងស្ថិរភាព នៅក្នុងតំបន់ រួមមានស្ថានការណ៍នៅក្នុងប្រទេសមីយ៉ាន់ម៉ា ផងដែរ៕

ថ្ងៃសុក្រ ២កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០២១